# ឯកសារព័ត៌មានអំពីក្រុមចំណីអាហារ #16

*ប្រការដែលអ្នកគួរយល់ដឹងអំពីក្រុម*

WWW.HEALTHOREGON.ORG/FOODSAFETY

## អាហារដែលត្រូវបានលើកលែងអាជ្ញាប័ណ្ណពីអាជ្ញាធរសុខភាពសាធារណៈក្នុងមូលដ្ឋាននៅក្នុងព្រឹត្តិការណ៍បណ្ដោះអាសន្ន

នៅរដ្ឋ Oregon ស្ថាប័ន ឬគ្រឹះស្ថានចំណីអាហារ ឬដែលរៀបចំ ឬលក់មុខអាហារខាងក្រោមសម្រាប់បរិភោគភ្លាមៗត្រូវបានលើកលែងពីអាជ្ញាប័ណ្ណ និងបទប្បញ្ញត្តិ ORS 624.010 ដល់ 624.120 និង ORS 624.310 ដល់ 440 មិនថាពួកគេប្រតិបត្តិការនៅកន្លែងព្រឹត្តិការណ៍ឬអត់ក៏ដោយ៖

- បង្អែមប្រភេទដុំស្ករដែលជាអាហារមិនអាចមានគ្រោះថ្នាក់ ដូចជាស្ករគ្រាប់ ឬបង្អែម មានជាអាទិ៍ ស្ករតាំងម៉ែដាក់អំបិល, ស្ករបីទឹកដោះគោ (fudge), ស្ករម៉ាសម៉ាឡូដុំ, ម៉ាសម៉ាឡូស្រោបសូកូឡា និងស្ករគ្រាប់រឹង។
- ការ៉េមកញ្ចប់សម្រាប់លក់ និងបង្អែមបង្កកដែលលក់សម្រាប់បុគ្គលម្នាក់ៗរៀងខ្លួន
- ផលិតផលជ្រក់សម្រាប់លក់ សាច់ងៀតកែច្នៃសម្រាប់លក់ គ្រាប់ផ្លែឈើ សាច់គ្រាប់ផ្លែឈើ ពោតលីង និងចំណីអាហាររេចខ្ចប់ស្រាប់ដូចជា ចំណិតដំឡូងបារាំងស្ងួយ, pretzels និងនំស្ងួយដុត (cracker)
- ភេសជ្ជៈដែលជាអាហារមិនអាចមានគ្រោះថ្នាក់ច្រកកំប៉ុង និងច្រកដបដែលមិនទាន់បើក រួមទាំងភេសជ្ជៈមានជាតិអាល់កុលសម្រាប់ទទួលទានភ្លាមៗ
- កាហ្វេនិងតែ ដែលមានគ្រឿងផ្សំដែលមិនអាចមានគ្រោះថ្នាក់
- ភេសជ្ជៈក្ដៅ ឬត្រជាក់ដែលមិនអាចមានគ្រោះថ្នាក់ដែលរៀបចំសម្រាប់ការទទួលទានភ្លាមៗពីកញ្ចប់ម្សៅលាយច្រកកញ្ចប់មួយៗដោយទ្បែក និងទឹកសុទ្ធច្រកដបសម្រាប់លក់
- អាហារ ឬភេសជ្ជៈដែលមិនអាចមានគ្រោះថ្នាក់ដែលស្ថាប័ន ឬអាជីវកម្មសេវាកម្មមិនមែនចំណីអាហារ ផ្ដល់ជាការគួរសមដល់អតិថិជនដោយមិនគិតថ្លៃ។

ចំពោះបញ្ជីពេញលេញអំពីសកម្មភាព/អាហារដែលត្រូវបានលើកលែង សូមមើល OAR 333-150-0000, ផ្នែក 1-201.10 និយមន័យ "គ្រឹះស្ថានចំណីអាហារ មិនរួមបញ្ចូល"។

គ្រឹះស្ថាន ឬស្ថាប័នដែលរៀបចំ ឬលក់មុខអាហារដែលមិនអាចមានគ្រោះថ្នាក់សម្រាប់ការទទួលទានភ្លាមៗនៅក្នុងព្រឹត្តិការណ៍ណាមួយ ត្រូវបានលើកលែងមិនបាច់សុំអាជ្ញាប័ណ្ណ បើសិនជា៖

- និយោជិតផ្នែកចំណីអាហារមិនប៉ះអាហារដែលលាត/គ្មានអ្វីគ្រប អាហារដែលអាចបរិភោគបានភ្លាមដោយដៃទទេ និងប្រើប្រដាប់ប្រដាសមស្របដូចជាក្រដាសសម្រាប់ហាងអាហារឆ្អិនស្រាប់ រ៉ែក តង្កៀប ស្រោមដៃដែលប្រើម្ដងចោល និងឧបករណ៍សម្រាប់ចែកចាយ ជាដើម
- មានផ្ដល់កន្លែងលាងដៃបណ្ដោះអាសន្ន៖




- ត្រូវបិទផ្សាយសេចក្ដីជូនដំណឹង* ឱ្យមើលឃើញជាសាធារណៈដែលចែងថា៖ "NOTICE: Food served at this location may not have been inspected by the regulatory authority" ឬជាភាសាស្រដៀងគ្នាដែលត្រូវបានអនុម័តដោយអាជ្ញាធរនិយ័តកម្ម (សូមមើលទំព័រ 2 សម្រាប់សញ្ញាដែលបោះពុម្ពចេញ)
- គ្រឿងផ្សំទាំងអស់ រួមទាំងទឹក និងទឹកកក ត្រូវតែមកពីប្រភពដែលត្រូវបានអនុម័ត រីឯផលិតផលត្រូវតែត្រូវបានផលិតដោយប្រើការអនុវត្តការគ្រប់គ្រងអាហារប្រកបដោយសុវត្ថិភាព។
- អ្នកលក់ទឹកក្រូចកៀបស្រស់ដូចជា ក្រូចឆ្មារលឿង ក្រូចឆ្មារបៃតង ក្រូចពោធិ៍សាត់ និងក្រូចថ្លុង ដែលតាំងបង្ហាញទឹកក្រូចទាំងនេះនៅទីតាំងនៃព្រឹត្តិការណ៍ ហើយរៀបចំនិងលក់ផលិតផលទាំងនេះសម្រាប់តែបរិភោគភ្លាមៗដោយបុគ្គលម្នាក់ៗរៀងខ្លួនប៉ុណ្ណោះ។

គ្រឹះស្ថានអាចបន្ថែមតែគ្រឿងផ្សំកែច្នៃសម្រាប់លក់ដែលមិនអាចមានគ្រោះថ្នាក់ប៉ុណ្ណោះ មិនរាប់បញ្ចូលបន្លែ ឬផ្លែឈើស្រស់ទេ។ បើសិនជាទឹកក្រូចកៀបស្រស់ត្រូវបានលក់ ឬបរិភោគដោយមិនត្រូវបានកែច្នៃជាពិសេសដើម្បីការពារ កាត់បន្ថយ ឬកម្ចាត់ភ្នាក់ងារបង្កជំងឺទេ នោះត្រូវតែបិទផ្សាយសេចក្ដីជូនដំណឹង*ខាងក្រោមនេះ "NOTICE: This product has not been pasteurized or processed"។

- គ្រឹះស្ថានដែលលក់ទឹកផ្លែឈើកៀបស្រស់ ក្រៅពីទឹកក្រូចកៀបស្រស់នៅកន្លែងព្រឹត្តិការណ៍ ត្រូវតែទទួលបានអាជ្ញាប័ណ្ណភោជនីយដ្ឋានបណ្ដោះអាសន្ន។



***ទំនិញដុត (ដូចជានំឃុកឃី ដូណាត់ ឬនំផាយផ្លែឈើ) ស្ករគ្រាប់ផ្លែជ៉ោម និង kombucha ឥឡូវនេះត្រូវបំពេញតាមលក្ខខណ្ឌទាមទារទាំងនេះ***

- [សំណុំបែបបទកិច្ចព្រមព្រៀងអាហារដែលលើកលែង] ត្រូវបានបំពេញ និងរក្សាទុកនៅទីតាំងព្រឹត្តិការណ៍ក្នុងអំឡុងម៉ោងប្រតិបត្តិការទាំងអស់។ អាចមានការគិតថ្លៃសម្រាប់ការត្រួតពិនិត្យសំណុំបែបបទឡើងវិញ ដោយនាយកដ្ឋានសុខភាពបរិស្ថានមូលដ្ឋានរបស់អ្នក។
- អាជ្ញាធរនិយ័តកម្មអាចនឹងទាមទារឱ្យមានអាជ្ញាប័ណ្ណគ្រឹះស្ថានចំណីអាហារ បើសិនជាមានកង្វល់អំពីសុវត្ថិភាពចំណីអាហារទាក់ទងនឹងប្រតិបត្តិការសេវាកម្មចំណីអាហារដែលលើកលែង។

អាហារដែលអាចមានគ្រោះថ្នាក់គឺជាអាហារដែលមានប្រភពពីសត្វ (ឆៅ ឬឆ្អិន), ផលិតផលពីរុក្ខជាតិឆ្អិន, ពន្លកគ្រាប់ឆៅ, ត្រសក់ស្រូវកាត់រួច, ល្បាយខ្ទឹមសនិងប្រេងឆា, ប៉េងប៉ោះកាត់រួច និងកសិផលបន្លែស្លឹកបៃតងកាត់រួចដែលឆៅ។ ឧទាហរណ៍មួយចំនួនមាន៖ ហត់ដក, ម្ទេស, បាយ, ដំឡូងបារាំងឆ្អិន និងសណ្ដែកឆ្អិន។

**ឧទាហរណ៍អាហារដែលត្រូវបានលើកលែងអាជ្ញាប័ណ្ណ និងមិនតម្រូវឱ្យបំពេញសំណុំបែបបទអាហារដែលលើកលែង**

- បង្អែមប្រភេទដុំស្ករដែលមិនអាចមានគ្រោះថ្នាក់ (ស្ករបីទឹកដោះគោ (fudge), ស្ករតាំងម៉ែដាក់អំបិល, ម៉ាសម៉ាឡូស្រោបសូកូឡា)
- ការរ៉េមកញ្ចប់សម្រាប់លក់ និងបង្អែមបង្អកដែលលក់សម្រាប់បុគ្គលម្នាក់ៗរៀងខ្លួន
- ផលិតផលជ្រក់សម្រាប់លក់ សាច់ងៀតកែច្នៃសម្រាប់លក់ គ្រាប់ផ្លែឈើ សាច់គ្រាប់ផ្លែឈើ ពោតលីង និងចំណីអាហារវេចខ្ចប់ស្រាប់ដូចជាចំណិតដំឡូងបារាំងស្រួយ, pretzels និងនំស្រួយដុត (cracker)
- ភេសជ្ជៈដែលជាអាហារមិនអាចមានគ្រោះថ្នាក់ច្រកកំប៉ុង និងច្រកដបដែលមិនទាន់បើក ដែលរាប់បញ្ចូលភេសជ្ជៈមានជាតិអាល់កុល
- កាហ្វេនិងតែ ដែលមានគ្រឿងផ្សំដែលមិនអាចមានគ្រោះថ្នាក់
- ភេសជ្ជៈក្តៅ ឬត្រជាក់ដែលមិនអាចមានគ្រោះថ្នាក់ដែលរៀបចំសម្រាប់ការទទួលទានភ្លាមៗពីកញ្ចប់ម្សៅលាយច្រកកញ្ចប់មួយៗដោយទ្បែក និងទឹកសុទ្ធច្រកដបសម្រាប់លក់ មិនរាប់បញ្ចូលទឹកបន្លែ/ផ្លែឈើច្របាច់

**ឧទាហរណ៍អាហារដែលមិនអាចមានគ្រោះថ្នាក់ (PHF) ដែលត្រូវបានលើកលែងនៅព្រឹត្តិការណ៍នានា បើសិនជាអាហារទាំងនោះបំពេញតាមលក្ខខណ្ឌទាមទារនៃអាហារដែលលើកលែង <u>និង</u>បំពេញសំណុំបែបបទ។**

- នំឃុកឃី
- ដូណាត់
- នំប៉័ងចៀន (នំត្រចៀកដំរី (elephant ears), នំហ្វាន់ណល (funnel cakes), នំប៉័ងចៀនបែបឥណ្ឌា (Indian fry bread)
- នំផាយផ្លែឈើ
- ផ្លែប៉ោមស្រោបស្ករ/ស្រោបស្ករតាំងម៉ែ
- ផ្លែឈើជ្រលក់សូកូឡា, ផ្លែឈើប្រភេទដែលមិនអាចមានគ្រោះថ្នាក់
- Kombucha (មានបន្ថែមតែគ្រឿងផ្សំដែលលើកលែង)
- ភេសជ្ជៈមានហ្គាសដាក់ទឹកកក
- ទឹកកកឈូសម៉ង្គ
- ទឹកកកឈូសគ្រីម
- ភេសជ្ជៈដាក់ទឹកកកឈូស (slushies) ដោយមានគ្រឿងផ្សំជាអាហារដែលមិនអាចមានគ្រោះថ្នាក់
- នំប៉័ង, នំប៉័ងមូល, នំម៉ាហ្វីន
- ទឹកក្រូចកៀប– សុទ្ធឬមានបន្ថែមគ្រឿងផ្សំជាអាហារដែលមិនអាចមានគ្រោះថ្នាក់សម្រាប់លក់ មិនរាប់បញ្ចូលបន្លែ ឬផ្លែឈើស្រស់ផ្សេងទៀត
- ទឹកផ្លែឈើសម្រាប់លក់ ដូចជាទឹកផ្លែប៉ោម Treetop ដែលលក់ដាក់កែវ

**ត្រូវតែរៀបចំអាហារទាំងអស់នៅទីតាំងព្រឹត្តិការណ៍ ឬនៅកន្លែងអាជីវកម្មដែលមានអាជ្ញាប័ណ្ណនៅមុនពេលព្រឹត្តិការណ៍។**

**ឧទាហរណ៍អាហារដែលទាមទារឱ្យមានអាជ្ញាប័ណ្ណនៅព្រឹត្តិការណ៍បណ្តោះអាសន្ន**

- ការ៉េមដួស
- ទឹកក្រឡុកផ្លែឈើ និង/ឬបន្លែ
- ឪឡឹកចំណិត
- ញាំបន្លែស្លឹកបៃតងកាត់រួច
- ទឹកផ្លែឈើ ឬបន្លែកៀប លើកលែងទឹកក្រូចកៀប
- បន្លែអាំង/ដុតដូចជា ពោតចម្អិនទាំងស្នូល
- អាហារដែលអាចមានគ្រោះថ្នាក់ចំពោះការបរិភោគភ្លាមៗ

*ថ្លៃរដ្ឋបាលអាចនឹងត្រូវបានគិតថ្លៃដោយអាជ្ញាធរនិយ័តកម្ម ដើម្បីពិនិត្យនិងអនុម័តសំណុំបែបបទកិច្ចព្រមព្រៀងអាហារដែលលើកលែង*

# NOTICE:

# Food served at this location may not have been inspected by the regulatory authority

*ជាចេតនា គេមិនបកប្រែសេចក្តីជូនដំណឹងនេះទេ